សុន្ទរកថាស្វាគមន៍

# ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្លែងក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ
លើប្រធានបទ “ឆាប់ធ្វើតេស្តឈាម ឆាប់ព្យាបាល  ឆ្ពោះទៅបញ្ចប់អេដស៍”

សាលសន្និសីទចតុមុខ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦

3

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមគោរពលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា និងរដ្ឋសភា

- ឯកឧត្តម William A. Heidt ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅកម្ពុជា
- លោកស្រី Maries-Odile Emond នាយកអង្គការUNAIDS ប្រចាំនៅកម្ពុជា
- ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកអគ្គរាជទូត រដ្ឋទូតតំណាងអង្គទូត លោក-លោកស្រីជាភ្ញៀវជាតិ អន្តរជាតិ ក្មួយៗនិស្សិត និងសិស្សានុសិស្សទាំងអស់ជាទីរាប់អាន!

ជាបឋមក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សមាជិក-សមាជិកានៃអង្គពិធីទាំងមូល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងបិតីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានរៀបចំ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៦ ដ៏មហោឡារិកនាពេលនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមអនុញ្ញាតសំដែងនូវគារវកិច្ចដ៏ឧត្តុងឧត្តម និង ដោយការគោរពដ៏ខ្ពង់ខ្ពស់ចំពោះការផ្តល់កិត្តិយសដ៏វិសេសវិសាលពី លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញចូលរួមជាអធិបតីនាពេលនេះ ដែលពិតជាបង្ហាញនូវការយកចិត្តទុកដាក់ប្រកប ដោយការប្តេជ្ញាចិត្តជានយោបាយដ៏មោះមុតរបស់ថ្នាក់ដឹកនាំកំពូលនៃរាជរដ្ឋាភិបាល កម្ពុជា និងជាឱកាសដ៏វិសេសវិសាលប្រកបដោយក្តីសង្ឃឹមយ៉ាងមុតមាំថា លោកជំទាវ នឹងផ្តល់នូវអនុសាសន៍ល្អៗដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ដៃគូអភិវឌ្ឍន៍ ធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ និងជាពិសេសដល់អង្គពិធីទាំងមូលយកទៅ អនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀតដើម្បីឆ្ពោះទៅសម្រេចបាននូវការប្តេជ្ញាចិត្តរបស់យើង ក្នុងការបញ្ចប់ការចម្លងមេរោគអេដស៍នៅត្រឹមឆ្នាំ២០២៥ នៅកម្ពុជាដែលជាការប្តេជ្ញាចិត្ត ប្រកបដោយមហិច្ឆតា និង ការទទួលខុសត្រូវខ្ពស់។

នៅក្នុងទិវាដ៏វិសេសវិសាលនេះ ខ្ញុំសូមអនុញ្ញាតជម្រាបជូន **លោកជំទាវឧបនាយករដ្ឋមន្ត្រី** ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី និងអង្គពិធីទាំងមូលមេត្តាជ្រាបថា ជារៀងរាលឆ្នាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងការប្តេជ្ញាចិត្តនយោបាយ

ដ៏មោះមុតបំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា យើងតែងតែចូលរួមជាមួយពិភពលោក ក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ដែលរៀបចំឡើងជាទៀងទាត់នៅទូទាំងពិភពលោកនៅរៀងរាល់ថ្ងៃទី១ធ្នូ ដោយប្រើប្រាស់សាររួមគ្នាមួយក្នុងគោលបំណងបង្ហាញពីឆន្ទៈចូលរួមជាមួយពិភពលោក ក្នុងការបញ្ចប់ការចម្លងមេរោគអេដស៍ នៅឆ្នាំ២០៣០។

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ក៏មានគោលបំណងលើកកម្ពស់ការយល់ដឹងព័ត៌មានថ្មីៗស្តីពីការរាលដាលមេរោគអេដស៍ និងចំណេះដឹងវិទ្យាសាស្ត្រប្រកបដោយ ប្រសិទ្ធភាពលើការងារទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ក៏ដូចជាការក្រើនរំលឹកដល់ប្រជាពលរដ្ឋទូទាំងប្រទេស ឱ្យចងចាំជានិច្ចពីគ្រោះថ្នាក់នៃការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ផងដែរ។ លើសពីនេះទៅទៀត ទិវានេះក៏មានបំណងក្នុងការស្វែងរកការគាំទ្របន្ថែមទៀតពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់ស្រទាប់ទាំងអស់ ក្នុងការចូលរួមវិភាគទានដល់ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងតំបន់ និង នៅលើពិភពលោកទាំងមូលក្រោមពាក្យស្លោក **“ឆាប់ធ្វើតេស្តឈាម ឆាប់ព្យាបាល ឆ្ពោះទៅបញ្ចប់អេដស៍”** ។

**លោកជំទាវឧបនាយករដ្ឋមន្ត្រីជាទីគោរព ឯកឧត្តម លោកជំទាវ លោក-លោកស្រីភ្ញៀវជាតិ និងអន្តរជាតិ ប្អូនៗ និស្សិត និងសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន**

គណៈប្រតិភូកម្ពុជា រួមជាមួយមេដឹកនាំនៃរដ្ឋជាសមាជិកទាំងអស់របស់អង្គការ សហប្រជាជាតិបានគាំទ្រនូវសេចក្តីថ្លែងការណ៍រួម នៃសន្និបាតអង្គការសហប្រជាជាតិស្តីពីការបញ្ចប់ការឆ្លងមេរោគអេដស៍នៅឆ្នាំ២០៣០ នៅបូរីញូយ៉ក កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ កន្លងទៅថ្មីៗនេះ ។ មេដឹកនាំទាំងអស់បានទទួលស្គាល់ថា ដើម្បីសម្រេចបានគោលដៅខាងលើ ត្រូវតែសម្រេចឱ្យបាននូវយុទ្ធសាស្ត្រពន្លឿនក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍ “On The Fast Track” នៅឆ្នាំ២០២០ ដោយកំណត់នូវសារៈសំខាន់នៃការផ្សារភ្ជាប់គ្នារវាងការឆ្លើយតបរវាងវិស័យសុខាភិបាលទៅនឹងវិស័យ អភិវឌ្ឍន៍ វិសមភាពយេនឌ័រ ការលុបបំបាត់ភាពក្រីក្រ ដែលជាកត្តាមួយដ៏មានសារៈ សំខាន់បំផុត។

ដើម្បីសម្រេចឱ្យបាននូវគោលដៅខាងលើ កម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍លើកទី៤ ឆ្នាំ២០១៥ ដល់២០២០ និង គោលការណ៍៧ចំណុចរបស់រាជរដ្ឋាភិបាល ព្រមទាំងយុទ្ធសាស្ត្រ ៩០ ៩០ ៩០។ លើសពីនេះទៅទៀតពាក្យស្លោកនេះក៏មានគោលបំណងលើកកម្ពស់នូវការចូលរួម និង ការប្តេជ្ញាចិត្តបន្ថែមទៀតពីថ្នាក់ដឹកនាំនៅគ្រប់កម្រិតទាំងអស់ ដោយចាប់ផ្តើមពីការដឹកនាំបុគ្គលផ្ទាល់ខ្លួនម្នាក់ៗឈានទៅការដឹកនាំក្នុងគ្រួសារ សង្គម ប្រទេស និង ពិភពលោកទាំងមូលឱ្យចាកផុតពីការគម្រាមកំហែងនៃមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈការកំណត់នូវ **“គោលដៅសូន្យបី”** គឺ **១) គ្មានការចម្លងមេរោគអេដស៍ថ្មី ២) គ្មានការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ និង ៣) គ្មានការស្លាប់ដោយសារជំងឺអេដស៍។**

នៅក្នុងឱកាសដ៏មហោឡារិកនេះ ខ្ញុំក៏សូមការអនុញ្ញាតពី **លោកជំទាវឧបនាយករដ្ឋមន្ត្រី** និងអង្គពិធីទាំងមូលបង្ហាញដោយសង្ខេបពីសមិទ្ធិផល និង ជោគជ័យជាគន្លឹះដែលប្រទេសកម្ពុជាទទួលបានលើការងារទប់ស្កាត់ការរីករាលដាលមេរោគអេដស៍នៅកម្ពុជាក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ។

- យោងតាមការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រ នៅត្រឹមឆ្នាំ២០១៥ នេះអត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យដែលមានអាយុពី១៥-៤៩ ឆ្នាំ នៅកម្ពុជាគឺមាន**០.៦%** ដែលបន្តធ្លាក់ចុះពី**០.៨%** នៅក្នុងឆ្នាំ២០១១ **០.៧%** នៅក្នុងឆ្នាំ២០១២ និង **១.៧%** នៅក្នុងឆ្នាំ១៩៩៨ មានន័យថាកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ចប់ការរីករាលដាលមេរោគអេដស៍ប្រកបដោយជោគជ័យ និង ប្រកបដោយក្តីសង្ឃឹមថានឹងបន្តធ្លាក់ចុះជាបន្តទៀតនៅឆ្នាំខាងមុខ។
- ចំពោះការថែទាំ និង ព្យាបាលវិញ ក៏កម្ពុជាអាចសម្រេចផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានរហូតដល់ទៅជាង៨០% ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍ និង មានសង្ឃឹមថានឹងអាចឈានទៅសម្រេចបាន ៩០% នៅក្នុងឆ្នាំ២០២០ ខាងមុខនេះ។

- ដោយឡែកមានអ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍ និង កុមារកំព្រា និងកុមាររងាយរងគ្រោះដោយសារជំងឺអេដស៍ប្រមាណជា៧០% ដែលតែងតែទទួលបាននូវការគាំទ្រសង្គម សេដ្ឋកិច្ច សុខភាព អប់រំ ។ល។ ជាពិសេស គឺតាមរយៈការងារមនុស្សធម៌ដែលមិនចេះនឿយហត់ និង មិនចេះរីងស្ងួតរបស់កាកបាទក្រហមកម្ពុជាក្រោមការដឹកនាំរបស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា និង ឥស្សរជនឆ្នើមថ្នាក់ជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកក្នុងការប្រយុទ្ធនឹងជំងឺអេដស៍។
- អ្វីដែលជាសមិទ្ធផលលេចធ្លោសម្រាប់ឆ្នាំនេះ គឺកំណើននូវអត្រាស្ត្រីមានផ្ទៃពោះដែលបានមកប្រើប្រាស់សេវាកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដោយអត្រាស្ត្រីមានផ្ទៃពោះបានធ្វើតេស្តឈាមរកមេរោគអេដស៍ និង បានទទួលការព្យាបាល បង្ការការចម្លងមេរោគអេដស៍ទៅកូនរហូតដល់ជាង៨០%។ ជាលទ្ធផលអត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅក្នុងឆ្នាំ២០១៦ គឺមានកម្រិតត្រឹមតែ៦%ប៉ុណ្ណោះ រួមនឹងក្តីសង្ឃឹមប្រកបដោយការជឿជាក់ថា កម្ពុជានឹងអាចចូលរួមជាមួយពិភពលោកក្នុងការបញ្ចប់ទាំងស្រុង នូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅត្រឹមឆ្នាំ២០២០ ខាងមុខនេះផងដែរ។

បើទោះបីជាកម្ពុជាយើងសម្រេចបាននូវសមិទ្ធផលដ៏ធំធេង ដោយទទួលបាននូវការកោតសរសើរពីអង្គការសហប្រជាជាតិ តែយើងនៅមានបញ្ហាប្រឈមជាច្រើនទៀតដូចជាៈ ស្ត្រីបម្រើសេវាកំសាន្ត (EW) បុរសស្រឡាញ់បុរស(MSM) អ្នកចាក់គ្រឿងញៀន(PWID) អ្នកប្លែងភេទ (TG) ក្រុមយុវវ័យ(Youth) ដែលអត្រាឆ្លងនៅមានកម្រិតខ្ពស់ ដោយទាមទារនូវការយកចិត្តជាពិសេសក្នុងការផ្តល់នូវសេវាការពារនៃការឆ្លងមេរោគ ការការពារ និង ការព្យាបាល។

ជារួមយោងតាមព័ត៌មានស្តីពីវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលក្នុងឆ្នាំ២០១៦ ដែលខ្ញុំបានជម្រាបជូនដោយសង្ខេបខាងលើនេះ អាចទាញនូវសេចក្តីសន្និដ្ឋានមួយ បានថាកម្ពុជាកំពុងតែដើរនៅលើផ្លូវមួយដ៏ត្រឹមត្រូវបំផុត ឆ្ពោះទៅសម្រេចបាននូវការបញ្ចប់ការឆ្លងមេរោគអេដស៍ទាំងស្រុងនៅឆ្នាំ២០២៥។

ជាថ្មីម្តងទៀត តាងនាមឲ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការប្តេជ្ញាចិត្តដ៏មោះមុតក្នុងភាពជាថ្នាក់ដឹកនាំកំពូល ប្រកបដោយ

គតិបណ្ឌិត និង បញ្ញាញាណដ៏ឧត្តុងឧត្តមរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និង សម្តេចកិត្តិ ព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រជានយោបាយ ជាយុទ្ធសាស្ត្រ ជាពិសេស គោលនយោបាយប្រើប្រាស់ស្រោមអនាម័យ១០០% នៅតាមគ្រឹះស្ថានកម្សាន្តសប្បាយទាំងអស់ និង សកម្មភាពមនុស្សធម៌ទូលំទូលាយ គាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និង ជនរងគ្រោះដោយសារជំងឺអេដស៍ និង ជាពិសេសការបង្កើននូវថវិកាជាតិជារៀងរាល់ឆ្នាំ ដើម្បីឲ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានលទ្ធភាពពង្រីកសកម្មភាពការងារ ជាយុទ្ធសាស្ត្ររបស់ខ្លួនបានជាប្រចាំ។

សូមថ្លែងអំណរគុណផងដែរ ជូនចំពោះសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី មូលនិធិសកល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ បណ្តាញក្រុមប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍ ។ល។ ដែលបាន ចូលរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចបាននូវសមិទ្ធផលជាទីមោទនៈសម្រាប់ប្រទេស កម្ពុជានាពេលនេះ។

មុននឹងបញ្ចប់ ខ្ញុំសូមការអនុញ្ញាតពីលោកជំទាវឧបនាយករដ្ឋមន្ត្រី និង អង្គពិធីទាំងមូល ផ្តល់នូវសារមួយចំនួនជូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដើម្បីបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុត របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍:

១. សូមប្រជាពលរដ្ឋទាំងអស់ សស្រាក់សស្រាំចូលរួម ក្នុងការបង្ការទប់ស្កាត់ការឆ្លងរាលដាលមេរោគអេដស៍ ឈានទៅបញ្ចប់ការរីករាលដាលទាំស្រុងនៅឆ្នាំ២០២៥។

២. បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ និង អតិថិជនទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវការ អនុវត្តគោលនយោបាយប្រើប្រាស់ស្រោមអនាម័យ១០០%។

៣. បុរសកម្ពុជាត្រូវចូលរួមយ៉ាងសកម្មក្នុងការទទួលខុសត្រូវចំពោះខ្លួនឯងផ្ទាល់ ភរិយា និង ដៃគូ ព្រមទាំងកូនចៅរបស់ខ្លួន ពីការចម្លងមេរោគអេដស៍ដោយប្រកាន់ខ្ជាប់នូវការប្រព្រឹត្តប្រកបដោយសុវត្ថិភាពឱ្យរួចផុតពីការចម្លងមេរោគអេដស៍។

៤. ក្មួយៗយុវវ័យទាំងអស់មិនត្រូវឆាប់ប្រឡូក នឹងការរួមភេទនោះទេ ហើយត្រូវចាកចេញឲ្យឆ្ងាយពីការប្រើប្រាស់គ្រឿងញៀន ដែលជាប្រភពគ្រោះថ្នាក់ខ្ពស់នៃការចម្លងមេរោគអេដស៍។

៥. ស្ត្រីមានផ្ទៃពោះទាំងអស់ត្រូវស្វែងរកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឲ្យបាន ទាន់ពេលវេលានៅតាមសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

៦. យើងទាំងអស់គ្នាត្រូវចូលរួមលុបបំបាត់ការរើសអើង និង មាក់ងាយដល់អ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ឲ្យបានជាដាច់ខាត ព្រោះថាអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍គឺជាជនរងគ្រោះ ជាសមាជិកនៃក្រុមគ្រួសារ ជាសមាជិកសហគមន៍ និងជាសមាជិកសង្គមរបស់យើង ដែលត្រូវការការគាំទ្រពីយើងទាំងអស់គ្នា។

៧. ចំពោះអ្នកដែលមានការប្រព្រឹត្តប្រឈមនឹងការចម្លងមេរោគអេដស៍ ត្រូវស្វែងរកនូវសេវាផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាមរកមេរោគអេដស៍ដែលមាននៅតាមប្រព័ន្ធសេវាសាធារណៈទូទាំងប្រទេសឲ្យបានឆាប់ ដើម្បីឈានទៅទទួលសេវាថែទាំ និងព្យាបាលឲ្យបានទាន់ពេលវេលា។

៨. អ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍ទាំងអស់ត្រូវស្វែងរកការថែទាំ និងព្យាបាលឲ្យបានឆាប់ ដោយគោរពនូវវេជ្ជបញ្ជារបស់គ្រូពេទ្យឲ្យបានខ្ជាប់ខ្ជួន ដើម្បីចៀសវាងឲ្យបាន នូវភាពស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថប្រឆាំងមេរោគអេដស៍ ដែលជាមូលហេតុធ្ងន់ធ្ងរនៃមរណៈភាពដោយសារជំងឺអេដស៍ ។

៩. រាល់ការឆ្លើយតបទៅនឹងមេរោគអេដស៍ និង ជំងឺអេដស៍ ត្រូវតែឈរលើគោលការណ៍សមធម៌ និង សមភាពយេនឌ័រ។

មុននឹងបញ្ចប់ ខ្ញុំសូមការគាំទ្រពី លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ដៃគូអភិវឌ្ឍន៍ទាំងអស់បន្ថែមទៀត ក្នុងការជួយបន្ត និង បង្កើនការគាំទ្រហិរញ្ញវត្ថុ ដើម្បីឲ្យ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានលទ្ធភាពអនុវត្តផែនការយុទ្ធសាស្ត្រជាតិលើកទី៤ របស់ខ្លួន ឈានទៅពង្រីកអត្រាគ្របដណ្ដប់ទៅលើភូមិសាស្ត្រក្រុមគោលដៅប្រឈមមុខខ្ពស់ និង អនុវត្តកម្មវិធី ពន្លឿនឆ្លើយតបមេរោគអេដស៍ និង ប្រកបដោយចីរភាពឈានទៅសម្រេចបាននូវការបញ្ចប់ការឆ្លងរីករាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរបវរសួស្ដីជូន លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមប្រកបដោយសុខភាពល្អ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លៀសវៃ និង សូមប្រសិទ្ធពរជូនអង្គពិធីទាំងមូលទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ និង ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងនូវការកោតសរសើរផងដែរ ចំពោះសមាជិក-សមាជិកានៃគណៈកម្មការរៀបចំអង្គពិធីទាំងអស់ ដែលបានប្រឹងប្រែងយកអស់កម្លាំងកាយចិត្តរៀបចំពិធីនេះប្រកបដោយភាពរលូន និង ទទួលជោគជ័យ៕

សូមអរព្រះគុណ និងសូមអរគុណ